# ជំពូកទី ១

## ១. សេចក្តីផ្តើម

### ១.១ គោលបំណងរបាយការណ៍

ដោយផ្អែកតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ដែលបានឡាយព្រះហស្តលេខាដោយសម្តេចព្រះ **នរោត្តម សីហនុ** (២៤ ធ្នូ ១៩៩៦) និង អនុក្រិត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានចុះហត្ថលេខាដោយលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** (១១ សីហា ១៩៩៩) នោះ គំរោងរោងចក្រវ៉ារីអគ្គិសនីសេសានក្រោមទី២ ត្រូវបានគេចាត់ទុកថាជាគំរោងខ្នាតធំមួយ ហើយដែលទាមទារអោយមានការវាយតំលៃពីហេតុប៉ះពាល់បរិស្ថានពេញលេញ។

គោលបំណងនៃរបាយការណ៍នេះ គឺដើម្បីបង្ហាញពីលទ្ធផលនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ទាំងអវិជ្ជមាន និងវិជ្ជមាន របស់គំរោងវារីអគ្គិសនីដោយរួមទាំងហេតុប៉ះពាល់ដោយផ្ទាល់ និង ហេតុប៉ះពាល់ដោយប្រយោល ទៅលើធនធាន ធម្មជាតិ និង ធនធានសង្គមទាំងនៅក្នុង និង នៅជុំវិញតំបន់គំរោង ។

ការសិក្សានឹងពិនិត្យមើលពីសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ហើយការរៀបចំនូវវិធានការបន្ធូរបន្ថយសំរាប់ហេតុប៉ះពាល់ជាអវិជ្ជមាននិមួយៗនៅពេលមុនគំរោងសាងសង់ ពេលសាងសង់ និង ពេលដំណើរការ។ ការវាយតំលៃហេតុបះពាល់បរិស្ថានត្រូវបានធ្វើឡើងដោយអនុលោមទៅតាមច្បាប់នៃកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា និង អនុក្រិត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងបទបញ្ញត្តិ និង ច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ។

### ១.២ ដំណាក់កាលនៃការរៀបចំគំរោង

គំរោងនេះធ្វើការសិក្សារៀបចំដោយក្រុមហ៊ុន PECC-1 របស់សាធារណរដ្ឋសង្គមនិយមវៀតណាម។ នៅពេលថ្មីៗនេះ ក្រុមហ៊ុន PECC-1 កំពុងធ្វើការសិក្សាពីសមិទ្ធិលទ្ធភាពសំរាប់រោងចក្រវារីអគ្គិសនីសេសានក្រោមទី ២។ ការសិក្សាពីសមិទ្ធិលទ្ធភាពត្រូវបានគេរៀបចំផែនការដោយត្រូវចំណាយពេលប្រាំពីរខែ (មករា ដល់ កក្កដា ២០០៨) ។ នៅផ្នែកមួយនៃការសិក្សាពីសមិទ្ធិលទ្ធភាពគំរោង ក្រុមហ៊ុន **ឃី ខនសាល់ធេន ខេមបូឌា** (KCC- ក្រុមហ៊ុនពិគ្រោះយោបល់កម្ពុជាក្នុងស្រុក) ត្រូវបានជ្រើសយកដោយក្រុមហ៊ុន PECC-1 អោយសិក្សាពីហេតុប៉ះពាល់បរិស្ថាន (EIA) ។ របាយការណ៍សិក្សា EIA នឹងត្រូវដាក់ជូនជាមួយនឹងរបាយការណ៍សិក្សាពីសមិទ្ធិលទ្ធភាព ទៅក្រសួងបរិស្ថាន (MoE) និង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) ដែលជាស្ថាប័នតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា សំរាប់

Draft

ការអនុម័តមុនពេលបន្តទៅដំណាក់កាលបន្ទាប់ទៀតរបស់គំរោង (ដំណាក់កាលរៀបចំប្លង់លំអិត សាងសង់ និង ប្រតិបត្តិការ) ។

## ១.៣ គោលបំណងនៃសេដ្ឋកិច្ចសង្គម និង បរិស្ថានរបស់គំរោង

គោលបំណងនៃសេដ្ឋកិច្ចសង្គមរបស់គំរោងសាងសង់រោងចក្រវារីអគ្គិសនីសេសានទី២ គឺដើម្បីបំពេញតំរូវការថាមពលសំរាប់រយះពេលមធ្យម និង រយះពេលវែងរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាសំរាប់ការនាំចេញនូវថាមពលដែលនៅសល់ ។ គំរោងនេះក៏ឆ្លើយតបដោយផ្ទាល់ទៅនឹងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលអណត្តិទីបី ដែលចែងថាៈ "ទិដ្ឋភាពសំខាន់បំផុតមួយនៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល គឺបន្តការអភិវឌ្ឍន៏វិស័យថាមពល អោយឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពទៅនឹងកំនើនតំរូវការ សំរាប់អគ្គិសនីដែលមានតំលៃទាប ។ ហេតុដូចនេះរាជរដ្ឋាភិបាលបានដាក់នូវអាទិភាពខ្ពស់ បង្កើននូវការទាក់ទាញដល់ការវិនិយោគវិស័យឯកជន និង ការចូលរួមនៅក្នុងផលិតកម្មអគ្គិសនី និង ការចែកចាយ...." (ដកស្រង់ចេញពី *យុទ្ធសាស្រ្តចតុកោណ ផ្នែកទី៣ ការអភិវឌ្ឍន៍វិស័យថាមពល និង បណ្តាញអគ្គិសនី, ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍អន្តរជាតិ ២០០៦-២០១០, ២៧ មករា ២០០៦, ដោយរាជរដ្ឋាភិបាលកម្ពុជា* ។

Draft

គំរោងនេះក៏មានគោលបំណងទាញនូវផលប្រយោជន៏ពីធនធានបរិស្ថានផងដែរ ជាពិសេសធនធានទឹកពីទន្លេសេសាន និង ទន្លេស្រែពកនៅក្នុងប្រទេសកម្ពុជា ។ នៅតំបន់ខ្សែទឹកលើនៃទន្លេសេសាន និង ទន្លេស្រែពកនៅក្នុងប្រទេសវៀតណាម មានគំរោងរោងចក្រវារីអគ្គិសនីជាច្រើនដែលបានដំណើរការ កំពុងសាងសង់ និង មានផែនការសាងសង់ ។ ដោយយោងទៅតាមឯកសារ "គំរោងវារីអគ្គិសនីនៅតំបន់អាងនៃទន្លេមេគង្គក្រោម ដែលបានប្រតិបត្តិការ កំពុងសាងសង់ និង មានផែនការ (លើសពី ១០ MW)" របស់ MRC កុម្ភៈ, ២០០៨ ទំនប់ទាំងនោះរួមមានរោងចក្រវារីអគ្គិសនី Yali និង Dray H'Linh 1 (ទំនប់បានដាក់អោយដំណើរការរួចហើយ) Plei Krong សេសានទី៣ សេសានទី៣A សេសានទី៤ (កំពុងសាងសង់) Dray H' Linh 2, Buon Kuop, Buon Tua Srah, Kontum លើ ស្រែពកទី៣ ស្រែពកទី៤ និង Duc Xuyen (មានផែនការ) ។

គោលបំណងសំខាន់នៃសេដ្ឋកិច្ចសង្គម និងបរិស្ថាន គឺដើម្បីធានាបានផងដែរថា តុល្យភាពត្រឹមត្រូវរវាងការបង្កើតថាមពលដែលផ្តល់ជាហេតុប៉ះពាល់ជាវិជ្ជមានរបស់វាដល់សេដ្ឋកិច្ចជាតិ និងហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម ដែលវាបង្កជាពិសេសទៅលើធនធានក្នុងតំបន់មូលដ្ឋាន និងរបស់សហគមន៏ ។ នៅកន្លែងដែលមានផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ចសង្គម និងបរិស្ថានក្នុងតំបន់ត្រូវបានកត់សំគាល់ច្បាស់លាស់ នោះវិធានការសំណងសមរម្យត្រូវតែបានផ្តល់អោយប្រសិនបើគំរោងធ្វើការសាងសង់ ។

## ១.៤ ប្រវត្តិគំរោង

ប្រទេសកម្ពុជាមានសក្តានុពលសំរាប់ការអភិវឌ្ឍន៍វារីអគ្គិសនីប្រហែល ១0000 MW ដែល ៥0% អាចបានពីស្ទឹងទន្លេសំខាន់ៗ ៤0%បានពីដៃទន្លេ និង ១0%បានពីតំបន់ឆ្នេរ ។ ប៉ុន្តែមានតែ ១៣ MW ប៉ុណ្ណោះត្រូវបានអភិវឌ្ឍន៍កន្លងមក រួមមានរោងចក្រវារីអគ្គិសនីអូរជុំ (១ MW) និង រោងចក្រវារីអគ្គិសនីគីរីរម្យ I (១២ MW), (ប្រភព: ដកស្រង់ចេញពីគោលនយោបាយធនធានទឹកថ្នាក់ជាតិ (មករា ២00៤), ផ្នែក ៤.២.២ "ទឹកសំរាប់ថាមពល") ។

ភាគឦសាននៃប្រទេសកម្ពុជាមានសក្តានុពលខ្ពស់ផងដែរសំរាប់ការអភិវឌ្ឍន៍វារីអគ្គីសនី ជាពិសេសនៅក្នុងទន្លេមេគង្គប្រទេសកម្ពុជា និង ដៃរបស់វា។ ទន្លេសេសានគឺជាដៃមួយរបស់ទន្លេមេគង្គដែលមានសក្តានុពលសំរាប់ការអភិវឌ្ឍន៍រោងចក្រវារីអគ្គិសនី។ ដោយផ្អែកតាមលទ្ធផលនៃការសិក្សាដំបូងសំរាប់ការអភិវឌ្ឍន៍ ទន្លេសេសានក្នុងប្រទេសកម្ពុជា វាត្រូវបានយល់ព្រមដោយរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលវៀតណាមនៅក្នុងសម័យប្រជុំលើកទី ៩ របស់គណៈកម្មការសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និង បច្ចេកវិជ្ជា នៅទីក្រុងភ្នំពេញនៅថ្ងៃទី ២១ សីហា ២00៧ (មើលឧបសម្ព័ន្ធ ១ក) ហើយអគ្គិសនីវៀតណាមនឹងត្រូវវិនិយោគនៅក្នុងការសាងសង់ លើគំរោងវារីអគ្គិសនីសេសានក្រោមទី ១/សេសានទី៥ និង សេសានក្រោម (សេសានក្រោមទី ២) (ប្រភព: របាយការណ៍ដំបូងរបស់គំរោងវារីអគ្គិសនី សេសានក្រោមទី ២, ហាណូយ កញ្ញា ២00៧, PECC-1) ។

ម្យ៉ាងវិញទៀត អនុលោមតាមអនុស្សរណៈយោគយល់គ្នាដែលបានចុះហត្ថលេខាដោយអគ្គិសនីវៀតណាម (EVN) និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (MIME) នៅថ្ងៃទី ១៥ ខែ មិថុនា ២00៧ (មើលឧបសម្ព័ន្ធ ១ក) នោះ EVN បានចុះកិច្ចសន្យាអោយក្រុមហ៊ុន PECC-1 រៀបចំការសិក្សាពីសមិទ្ធិលទ្ធភាពសំរាប់គំរោងវារីអគ្គិសនី សេសានក្រោមទី២ ។ ក្រុមហ៊ុនឃីខនសាល់ធេនខេមបូឌា (KCC) ត្រូវបានផ្តល់កិច្ចសន្យាដោយ PECC-1 ដើម្បីអនុវត្តការសិក្សា EIA សំរាប់គំរោងវារីអគ្គិសនីសេសានក្រោមទី២ ដែលជាផ្នែកមួយនៃការសិក្សាពីសមិទ្ធិលទ្ធភាពរបស់គំរោង។

## ១.៥ ទំហំដែន និង មាតិកាសង្ខេបរបស់របាយការណ៍

ទំហំដែននៃការសិក្សា EIA គ្របដណ្តប់ទាំងគុណប្រយោជន៍របស់បរិស្ថាន និង សង្គម លេចចេញពីគ្រប់ទិដ្ឋភាពទាំងអស់របស់គំរោង នៅក្នុងការកំណត់យ៉ាងទូលំទូលាយនៃចំណាត់ថ្នាក់ធនធានបរិស្ថាន និង គុណតំលៃវា :- បរិស្ថានរូបសាស្ត្រ រួមមាន ដី ទឹក និង បរិយាកាស ។ បរិស្ថានជីវសាស្ត្ររួមមាន សត្វ និង រុក្ខជាតិដែលរស់នៅលើផែនដី និង នៅក្នុងទឹក ព្រមជាមួយនឹងជំរករបស់វា ។ បរិស្ថានសង្គម ដែលរាប់បញ្ចូលនូវ ហេដ្ឋារចនាសម្ព័ន្ធរូបសាស្ត្រ សេវាកម្ម និងគ្រឿងបរិក្ខាបំរើអោយសុខមាលភាព ការងារ ការអប់រំ និង ការអភិវឌ្ឍន៍សេដ្ឋកិច្ចទូទៅ ព្រមទាំងតំបន់វប្បធម៌ វត្ថុបុរាណ និង គុណភាពនៃតំលៃជីវិតរស់នៅ ។

Draft

មាតិកាសង្ខេបនៃរបាយការណ៍នេះរួមមានដប់ជំពូកដូចតទៅៈ ប្រវត្តិរបស់គំរោងមានរៀបរាប់នៅជំពូកទី១ ។ នីតិកម្ម និងបទបញ្ញត្តិសំខាន់ៗដែលទាក់ទងទៅនឹងប្រភេទ និង សកម្មភាពទាំងឡាយរបស់គំរោង មានបង្ហាញក្នុងជំពូកទី២ ។ ការពិណនាជាទូទៅពីសមាសធាតុរបស់គំរោង មានរៀបរាប់នៅក្នុងជំពូកទី៣ ។ ស្ថានភាពដើមដែលទាក់ទងទៅនឹងធនធានបរិស្ថានដែលមានស្រាប់ មានរៀបរាប់ក្នុងជំពូកទី៤។ ជំរើសនានារបស់គំរោង មានបង្ហាញនៅក្នុងជំពូកទី៥ ដែលលើកឡើងពីការធ្វើយុត្តិកម្មសំរាប់ទំរង់គំរោងស្នើសុំ ធៀបទៅនឹងលទ្ធភាពផ្សេងៗទៀត។ នៅក្នុងជំពូកទី៦ មានរៀបរាប់ពីការវាយតំលៃទៅលើហេតុប៉ះពាល់បរិស្ថាន និងវិធានការបន្ធូរបន្ថយ ។ ការជួបប្រជុំសាធារណៈ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធគំរោង និង ប្រជាជនដែលទទួលរងផលប៉ះពាល់ មានរៀបរាប់នៅក្នុងជំពូកទី៧។ ផែនការគ្រប់គ្រងបរិស្ថាន (EMP) មានរៀបចំនៅក្នុងជំពូកទី៨ ហើយការវាយតំលៃពីសេដ្ឋកិច្ចសំរាបគំរោងមានពណ៌នានៅក្នុងជំពូកទី៩។ នៅចុងបញ្ចប់គឺជំពូកទី ១០ ដែលមានរៀបរាប់ពីសេចក្តីសន្និដ្ឋាន និង អនុសាសន៍ទៅលើការសិក្សាពី EIA ទាំងមូល ។

## ១.៦ វិធីសាស្ត្រ

មាតិកានៃរបាយការណ៍ EIA គឺអនុលោមទៅតាមអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់រាជរដ្ឋាភិបាលកម្ពុជា (លេខ ៧២ អនក្រ.បក ខែសីហា ឆ្នាំ ១៩៩៩) និង គោលការណែនាំសំរាប់រៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់ក្រសួងបរិស្ថាន ហើយស្របទៅតាមគោលការណែនាំវាយតំលៃបរិស្ថាន របស់ធនាគារអភិវឌ្ឍន៍អាស៊ី ( ADB, Environmental Assessment Guideline , August 2003) ។

Draft

ការធ្វើ EIA គិតគូរទៅលើអន្តរអំពើរវាងសមាសធាតុគំរោង និង លក្ខណៈបរិស្ថាន។ អន្តរអំពើផ្តល់នូវការកើតឡើងទាំងហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន។ ផលប្រយោជន៍ផ្សេងៗ ត្រូវបានកត់ចំណាំ ហើយហេតុប៉ះពាល់អវិជ្ជមាន ត្រូវបានកាត់បន្ថយតាមរយៈការ រៀបចំប្លង់គំរោង និងតាមរយៈការអនុវត្តន៍ការងារ។ វិធានការទូទាត់ ឬ សំណងតាមទំរង់ផ្សេងៗនឹងត្រូវធ្វើជាចាំបាច់ សំរាប់ហេតុប៉ះពាល់ដែលមិនអាចគណនាបាន។ ហេតុប៉ះពាល់អវិជ្ជមានក៏អាចត្រូវបង្ហាញជាតួលេខនៅក្នុង ការវិភាគសេដ្ឋកិច្ចបរិស្ថានផងដែរ ។ ដើម្បីធានាបានពីការរៀបចំអោយបានល្អ និង មានភាពរលូនសំរាប់ការសិក្សា EIA វិធីសាស្ត្រទូទៅមានរៀបរាប់ដូចខាងក្រោមៈ

### *១. ការប្រមូលទិន្នន័យ និង ការពិនិត្យមើល*

- ការប្រមូលទិន្នន័យជាក់ស្តែង និង ទិន្នន័យដែលមានស្រាប់នៅ ទីក្រុងភ្នំពេញ ខេត្តស្ទឹងត្រែង និង ខេត្តរតនៈគីរី ទាក់ទងទៅនឹងច្បាប់ គោលនយោបាយ បទបញ្ញត្តិ ជីវចំរុះ ជីវភាពរស់នៅដែលពឹងពាក់ជលផលជាពិសេស ទិន្នន័យសេដ្ឋកិច្ចសង្គម និង ទិន្នន័យផ្សេងទៀតទាក់ទងទៅនឹងគំរោង ។

- ពិនិត្យមើលលើរបាយការណ៍បច្ចេកទេស និងរបាយការណ៍សមិទ្ធិលទ្ធភាពរបស់គំរោង និង ឯកសារដែលទាក់ទងផ្សេងទៀតទៅនឹងការអនុញ្ញាតិអោយវិនិយោគរបស់គំរោង ។

## ២. ការជួបប្រជុំ និង ការពិគ្រោះយោបល់

- ការជួបប្រជុំ និង ការពិគ្រោះយោបល់ជាមួយស្ថាប័នសំខាន់ៗទាក់ទងទៅនឹងគំរោងត្រូវបានធ្វើឡើងនៅទីក្រុងភ្នំពេញ ខេត្តស្ទឹងត្រែង និង ខេត្តរតនះគីរី ដោយរួមបញ្ចូលទាំងមន្ទីរបរិស្ថាន (DoE) មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មន្ទីរសាធារណការ និងដឹកជញ្ជូន (DPWT), មន្ទីរទេសចរណ៍ (DoT) មន្ទីរផែនការ (DoP), បណ្តាញការពារទន្លេ សេសាន ស្រែពក និងសេកុង (3SPN), សមាគមន៍ថែរក្សាបរិស្ថាន និង វប្បធម៌ (CEPA), WWF, BirdLife អន្តរជាតិ និង អង្គការផ្សេងទៀត ។
- ការប្រជុំ និង ពិគ្រោះយោបល់ជាមួយនឹងសហគមន៍ ឬអ្នកភូមិនៅក្នុងតំបន់ទទួលរងផលប៉ះពាល់ដោយផ្ទាល់ ដោយសារទីតាំងគំរោង (ជាពិសេសនៅក្នុងតំបន់ដែលលិចលង់ និង ស្ថិតនៅខ្សែទឹកខាងក្រោមនៃទីតាំងគំរោង) នៅក្នុងឃុំចំនួន ៤ (ឃុំ ស្រែគរ តាឡាត់ ក្បាលរមាស និង ឃុំភ្លុក ) របស់ស្រុកសេសាន ក្នុងខេត្តស្ទឹងត្រែង និង ឃុំមួយ (ឃុំស្រែអង្គ្រង) របស់ស្រុកកូនមុំ ក្នុងខេត្តរតនះគីរី ដែលនៅជាប់ខាងលើអាងទឹកស្តើស៊ុំរបស់គំរោង ។

## ៣. ការចុះអង្កេតទៅលើធនធានធម្មជាតិ

- ភូគព្ភសាស្ត្រ និង ដី (ទិន្នន័យពីរបាយការណ៍សិក្សាពីសមិទ្ធិលទ្ធភាពគំរោង)
- ត្រី និង ប្រភេទវារីភាវរស់នៅក្នុងតំបន់គំរោង (វិធីសាស្ត្រលំអិតមានបង្ហាញនៅក្នុងរបាយការណ៍សិក្សាអំពីត្រី នៅឯកសារភ្ជាប់ទី ២)
- ការធ្វើតេស្ត ឬការពិនិត្យគុណភាពទឹក (ការធ្វើតេស្តនៅទីវាល ដងយកគំរូសាកទឹក និងការធ្វើពិសោធន៍នៅក្នុងមន្ទីរពិសោធន៍គុណភាពទឹករបស់ក្រសួងធនធានទឹកនៅភ្នំពេញ)
- ការពិនិត្យគុណភាពខ្យល់ដែលមានស្រាប់ (ការវាស់វែងគុណភាពខ្យល់ក្នុងទីតាំងគំរោង ដោយប្រើឧបករណ៍ និង អ្នកឯកទេសពីមន្ទីរពិសោធន៍គុណភាពខ្យល់របស់ក្រសួងបរិស្ថាន )
- ការសិក្សាពីសត្វព្រៃ និងជំរកព្រៃឈើ (ការធ្វើសំយោគលើរបាយការណ៍សិក្សាស្រាវជ្រាវមានស្រាប់ និងការចុះសិក្សា អង្កេតនៅទីវាលក្នុងតំបន់គំរោង ហើយវិធីសាស្ត្រលំអិតមាននៅឯកសារភ្ជាប់ទី ៣)
- ការសិក្សាលើធនធានព្រៃឈើ (មានការថតរូបភាពពីលើអាកាសអំឡុងពេលសិក្សា កុម្ភះ ដល់មិនា ២០០៨ ដែលមានចំនួនសរុប ៤៥ផ្ទាំង ដែលទំហំផ្ទៃរូបថតមួយផ្ទាំងគឺ ១គ.ម$^{2}$ ។ ការចុះរាប់ព្រៃឈើតាមប្រភេទព្រៃ ការគណនាជីវម៉ាស់ និងការគណនាជាទឹកប្រាក់ )

Draft

## ៤. ការចុះអង្កេតទៅលើធនធានសង្គម

- ដីប្រើប្រាស់ ( មានប្រើផែនទី JICA ឆ្នាំ 2003 មាត្រដ្ឋាន 1:100000, Landsat (TM) ឆ្នាំ 2000, រូបថតពីលើអាកាសឆ្នាំ 2001-2002, និងទិន្នន័យបានពីអាជ្ញាធរ ឃុំ ស្រុក នៅក្នុងខេត្តស្ទឹងត្រែង)
- ប្រជាពលរដ្ឋនៅក្នុងតំបន់គំរោង និង កំណត់ចំនួនប្រជាជនដែលរងផលប៉ះពាល់ (ការចុះអង្កេតដល់ភូមិ ឃុំផ្ទាល់ និងប្រើប្រាស់លទ្ធផលសិក្សាវាយតំលៃការខូចខាតនៃរបាយការណ៍ការតាំងលំនៅដ្ឋានសារជាថ្មី)
- ការតាំងទីលំនៅសារជាថ្មី (ប្រើប្រាស់លទ្ធផលពីក្រុមសិក្សាការតាំងទីលំនៅសារជាថ្មី របស់ PECC1)
- សកម្មភាពសេដ្ឋកិច្ច និងការអភិវឌ្ឍន៍របស់សហគមន៍នៅក្នុងតំបន់គំរោង (ការចុះអង្កេតតាមភូមិ ឃុំផ្ទាល់ និងការសំភាសលើការសិក្សាមានស្រាប់ ហើយវិធីសាស្ត្រលំអិតមានបង្ហាញនៅក្នុងរបាយការណ៍សិក្សាសេដ្ឋកិច្ចសង្គម ក្នុងឯកសារភ្ជាប់ទី ៤)
- ហេដ្ឋារចនាសម្ព័ន្ធបំរើអោយការប្រើប្រាស់របស់មនុស្ស និង គុណភាពនៃជីវិតរស់នៅ(ការចុះអង្កេតតាមភូមិ ឃុំផ្ទាល់ និងការសំភាសលើការសិក្សាមានស្រាប់)

## ៥. ការវិភាគ និង ការវាយតំលៃពីសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន

- ហេតុប៉ះពាល់ទៅលើធនធានធម្មជាតិ
- ហេតុប៉ះពាល់ទៅលើធនធានសង្គម
- ហេតុប៉ះពាល់ផ្សេងៗទៀត
- បណ្តុំនៃហេតុប៉ះពាល់

## ៦. ការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន EIA

- របាយការណ៍មានទំរង់ទៅតាមគោលការណ៍នាំរបស់ក្រសួងបរិស្ថាន និង គោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងផ្អែកលើឯកសារយោង (ToR) ដែលផ្តល់ដោយ PECC-១, សូមមើលសេចក្តីបន្ថែមទី ១។
- ផែនទី GIS និង រូបថតត្រូវបានដាក់បញ្ចូល។
- ការប៉ាន់ប្រមាណពីសេដ្ឋកិច្ចបរិស្ថាន និង តំលៃ និងផលប្រយោជន៍គំរោងត្រូវបានផ្តល់ផងដែរ។
- ការដាក់បញ្ចូលវិធានការបន្ធូរបន្ថយដើម្បីកាត់បន្ថយទំហំ នៃហេតុប៉ះពាល់លើទីតាំង ឬ ទីកន្លែងគំរោងការរៀបចំបឋម ការស្ថាបនា និង ដំណាក់កាលប្រតិបត្តិគំរោង។
- ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន ដើម្បីប្រើប្រាស់កំឡុងពេលសាងសង់ និង ប្រតិបត្តិការ។

Draft